ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ០៧ អយក.សណន

# សេចក្ដីណែនាំ
## ស្ដីពី
## ការបង្ការ ទប់ស្កាត់ការគំរាមកំហែង និងឆបោកលើកុមារ

កន្លងមក ក្រសួងអប់រំ យុវជន និងកីឡាសង្កេតឃើញថា មានករណីជនខិលខូចនាំកុមារទៅកន្លែងស្ងាត់ដើម្បីបន្លំដោះយកគ្រឿងអលង្ការ ឬមានការគំរាមកំហែងយកប្រាក់ គ្រឿងអលង្ការ និងសកម្មភាពផ្សេងទៀតពាក់ព័ន្ធនឹងការឆបោកលើកុមារ។

ដើម្បីពង្រឹងសន្តិសុខ បង្ការ ទប់ស្កាត់សកម្មភាពអសកម្មទាំងនេះ សំដៅការពារកុមារឱ្យទទួលបានការអប់រំប្រកបដោយសុវត្ថិភាពស្របតាមគោលនយោបាយ ស្ដីពីកិច្ចការពារកុមារនៅសាលារៀន ក្រសួងអប់រំ យុវជន និងកីឡា សូមធ្វើការណែនាំដូចខាងក្រោម៖

១. **មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត** ត្រូវសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការកំណត់មុខសញ្ញាជនសង្ស័យ បង្ការ ទប់ស្កាត់កុំឱ្យធ្វើសកម្មភាពខាងលើ ព្រមទាំងផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីសកម្មភាពល្មើសច្បាប់ និងល្បិចកលជនខិលខូចដល់មាតាបិតា ឬអ្នកអាណាព្យាបាល និងសិស្សានុសិស្ស ដើម្បីបង្កើនការប្រុងប្រយ័ត្ន និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ចនៅមូលដ្ឋាន។

២. **អភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**
- ពង្រឹងសន្តិសុខ សុវត្ថិភាពនៅតាមគ្រឹះស្ថានសិក្សា
- កំណត់មុខសញ្ញាជនសង្ស័យដើម្បីបង្ការ ទប់ស្កាត់កុំឱ្យធ្វើសកម្មភាពគំរាមកំហែង ឆបោកនិងបទល្មើសផ្សេងទៀត
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីសកម្មភាពល្មើស និងល្បិចកលជនខិលខូចដល់មាតាបិតា ឬអ្នកអាណាព្យាបាល និងសិស្សានុសិស្ស ដើម្បីបង្កើនការប្រុងប្រយ័ត្ន
- មានវិធានការបន្ទាន់ជួយដល់កុមាររងគ្រោះ និងងាយរងគ្រោះ
- ចាត់វិធានការអប់រំណែនាំ និងអនុវត្តតាមផ្លូវច្បាប់ចំពោះជនប្រព្រឹត្តបទល្មើស
- ជំរុញនិងលើកទឹកចិត្តមាតាបិតា ឬអ្នកអាណាព្យាបាលឱ្យចូលរួមសហការផ្ដល់ព័ត៌មានអំពីមុខសញ្ញាជនខិលខូច
- ជំរុញការអនុវត្តគោលការណ៍ "សាលារៀនមួយ តំបន់សុខសាន្តមួយ"
- ទប់ស្កាត់អំពើហិង្សាគ្រប់ទម្រង់លើកុមារ។

៣. **គណៈគ្រប់គ្រងសាលារៀន និងគ្រូបង្រៀន**
- ធ្វើការណែនាំដល់សិស្សានុសិស្សជាប្រចាំ និងផ្សព្វផ្សាយអំពីករណីឆបោកនិងគំរាមកំហែងនាពេលកន្លងមក ដើម្បីសិស្សានុសិស្សបានដឹង និងបង្កើនការប្រុងប្រយ័ត្ន
- បង្កើត ឬធ្វើបច្ចុប្បន្នកម្មបញ្ជីឈ្មោះ លេខទូរស័ព្ទផ្ដល់ព័ត៌មាន ឬបណ្ដាញទំនាក់ទំនងសង្គមទាន់ហេតុការណ៍ និងផ្សព្វផ្សាយឱ្យបានទូលំទូលាយ

១/សូត្រ២

- រាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមានសមត្ថកិច្ច កងកម្លាំងប្រដាប់អាវុធ ដើម្បីស្រាវជ្រាវនិងតាមចាប់ខ្លួនមុខសញ្ញាជនដែលជល់
- សហការជាមួយអាជ្ញាធរមានសមត្ថកិច្ច និងអ្នកពាក់ព័ន្ធ ដើម្បីផ្សព្វផ្សាយ បង្ការទប់ស្កាត់នូវរាល់សកម្មភាពគំរាមកំហែង និងឆបោកពីជនទុច្ចរិត
- ជំរុញនិងលើកទឹកចិត្តមាតាបិតា ឬអ្នកអាណាព្យាបាលឱ្យសហការផ្តល់ព័ត៌មានទាក់ទងនឹងល្បិចកលជនខិលខូច
- ស្វែងរកដំណោះស្រាយនានានៅពេលមានផលប៉ះពាល់លើសុខុមាលភាពកុមារខាងផ្លូវកាយ ផ្លូវចិត្ត ផ្លូវអារម្មណ៍។

៤. មាតាបិតា ឬអ្នកអាណាព្យាបាល និងសិស្សានុសិស្ស

- មាតាបិតា ឬអ្នកអាណាព្យាបាល ត្រូវអប់រំណែនាំកូនចៅជាប្រចាំអំពីការបង្ការ ទប់ស្កាត់សកម្មភាព លួងលោម ឆបោករបស់ជនទុច្ចរិត
- សិស្សានុសិស្សត្រូវប្រុងប្រយ័ត្ននៅពេលធ្វើដំណើរទៅទីកន្លែងណាមួយដាច់ឆ្ងាយពីគេត្រូវមានគ្នាចាប់ពី ២(ពីរ)នាក់ឡើងទៅ
- សិស្សានុសិស្សត្រូវចៀសវាងទៅកន្លែងស្ងាត់ជាមួយជនមិនស្គាល់មុខ ឬ ស្គាល់មិនច្បាស់
- សិស្សានុសិស្សត្រូវបដិសេធចំពោះការបបួលរបស់ជនមិនស្គាល់មុខ និងប្រញាប់គេចចេញឆ្ងាយពីអ្នកបបួល ឬ រត់ទៅរកអ្នកដទៃឱ្យជួយ
- សិស្សានុសិស្សមិនត្រូវធ្វើតាមបញ្ជារបស់ជនមិនស្គាល់មុខ ឬមិត្តភក្តិដែលមានបំណងមិនល្អចំពោះខ្លួន
- សិស្សានុសិស្សត្រូវណែនាំអំពីល្បិចកលជនខិលខូចដែលខ្លួនធ្លាប់ដឹង ដល់មិត្តភក្តិ និងអ្នកដទៃទៀត
- សិស្សានុសិស្សត្រូវរាយការណ៍ជាបន្ទាន់ទៅ លោកគ្រូ អ្នកគ្រូ គណៈគ្រប់គ្រងសាលារៀន ក្នុងករណីដែលមានសកម្មភាពកើតឡើងចំពោះខ្លួន ឬមិត្តភក្តិ។

ទទួលបានសេចក្តីណែនាំនេះ មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សាសាធារណៈនិងឯកជន បុគ្គលិកអប់រំ អាជ្ញាធរមានសមត្ថកិច្ច មាតាបិតា ឬ អ្នកអាណាព្យាបាលគ្រប់រូប ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃព្រហស្បតិ៍ ១៥កើត ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- គ្រប់អង្គភាពក្រោមឱវាទទីស្តីការក្រសួង

**"ដើម្បីជ្រាបជាព័ត៌មាន"**

- គ្រប់រដ្ឋបាលរាជធានី ខេត្ត

**"ដើម្បីជំរុញការអនុវត្ត"**

- គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- គ្រប់រដ្ឋបាលក្រុង ស្រុក ខណ្ឌ
- គ្រប់គ្រឹះស្ថានសិក្សាសាធារណៈ និងឯកជន

**"ដើម្បីអនុវត្ត"**

- កាលប្បវត្តិ
- ឯកសារ នាយកដ្ឋាននីតិកម្ម